**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**លេខ:..១៦០ សសរ ក.ស.វ.**

# សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត

## ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
## ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នសរ/កម ០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញអនុក្រឹត្យលេខ៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សម្រេច

**ប្រការ១..**

ត្រូវបានបង្កើតក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលសរសេរជាអក្សរកាត់ថា ក.ប.ល. ។



បន្ទប់លេខ ២២៣ ជាន់ទី២ ស្លាបខាងកើត ទូរសារ / ទូរស័ព្ទ:(855) 23 219 121 ទូរស័ព្ទចល័ត: (855) 12 698 999 / Email: pchsokha@yahoo.co.uk

**ប្រការ២.-**

ក.ប.ល. មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រីក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង ស្ថាប័ន អំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (កម្មវិធី វ.ផ.ល.)
- ផ្តល់យោបល់ជូនក្រសួង ស្ថាប័ន ក្នុងការរៀបចំរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ធ្វើបច្ចុប្បន្នកម្ម រៀបចំបោះពុម្ព និងផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

**ប្រការ៣.-**

ក.ប.ល. មានសមាសភាព និងតួនាទីភារកិច្ចដូចខាងក្រោម៖

**ក. សមាសភាព**

| | | |
|---|---|---|
| ១. ឯកឧត្តម **យឹម ណុលសន** | អនុប្រធានប្រចាំការក.ស.វ. | ប្រធាន |
| ២. ឯកឧត្តម **នរ៉ាណារឫទ្ធិ អានន្ទយ៉ាត** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអនុប្រធាន ក.ស.វ. | អនុប្រធាន |
| ៣. ឯកឧត្តម **ស្នួង លាងហៃ** | សមាជិក ក.ស.វ. | អនុប្រធាន |
| ៤. ឯកឧត្តម **ម៉ិច សុខា** | សមាជិកក.ស.វ.និងជាអគ្គលេខាធិការរង | អនុប្រធានប្រចាំការ |
| ៥. ឯកឧត្តម **ឌិន ធីរៈ** | សមាជិក ក.ស.វ. | សមាជិក |
| ៦. ឯកឧត្តម **ម៉ែន សារឿន** | សមាជិក ក.ស.វ. | សមាជិក |
| ៧. ឯកឧត្តម **អេង រត្នមុនី** | អគ្គលេខាធិការរង | សមាជិក |
| ៨. ឯកឧត្តម **ឡោ ម៉ូលីណា** | អគ្គលេខាធិការរង | សមាជិក |
| ៩. ឯកឧត្តម **ហេង ទិដ្ឋា** | អគ្គលេខាធិការរង | សមាជិក |
| ១០. ឯកឧត្តម **សំ សំណាង** | ប្រធានផ្នែកលិខិតបទដ្ឋានគតិយុត្ត នៃអគ្គលេខាធិការដ្ឋានក.ស.វ. | លេខាធិការ |
| ១១. លោក **ពិន សុធា** | ប្រធានផ្នែកសិក្សាស្រាវជ្រាវនិងអង្កេត នៃអគ្គលេខាធិការដ្ឋានក.ស.វ. | លេខាធិការ |

១២. លោក **អៀង រដ្ឋា** ប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងពត៌មាននៃអគ្គលេខាធិការដ្ឋានក.ស.វ. លេខាធិការ

១៣. លោក **ឃឹម ច័ន្ទតារា** អនុប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យនិងពត៌មាននៃអគ្គលេខាធិការដ្ឋានក.ស.វ លេខាធិការ

**ខ. តួនាទីភារកិច្ច**

- ដឹកនាំ ក.ប.ល. ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងជួបប្រជុំជាមួយថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ដៃគូរអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងៗ
- រៀបចំផែនការមេ ផែនការសកម្មភាព និងគម្រោងថវិកាកម្មវិធីសម្រាប់កម្មវិធី វ.ផ.ល. ជូនឯកឧត្តមប្រធាន ក.ស.វ. ដើម្បីពិនិត្យសម្រេច
- ដឹកនាំការងារកែសម្រួល ឬការងារធ្វើបច្ចុប្បន្នកម្មរាល់ឯកសារណែនាំស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីឲ្យស្របទៅនឹងសភាពការណ៍ជាក់ស្តែង
- រៀបចំប្រភពមូលដ្ឋានទិន្នន័យ ថែរក្សា និងធ្វើបច្ចុប្បន្នកម្មទិន្នន័យ សម្រាប់គាំទ្រដល់ការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- រាយការណ៍អំពីវឌ្ឍនភាពនៃកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តជូនឯកឧត្តមប្រធាន ក.ស.វ.
- ទទួលភារកិច្ចផ្សេងទៀតទៅតាមការប្រគល់ជូនរបស់ឯកឧត្តមប្រធាន ក.ស.វ. ។

**ប្រការ៤.**

ក.ប.ល. ប្រើប្រាស់កញ្ចប់ថវិការបស់ ក.ស.វ. សម្រាប់ដំណើរការ។

**ប្រការ៥.**

សេចក្តីសម្រេចលេខ០៣ សសរ-ក.ស.វ. ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អនុប្រធានប្រចាំការ អនុប្រធាន សមាជិក ក.ស.វ. អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក អនុប្រធានផ្នែករបស់អគ្គលេខាធិការដ្ឋាននៃក.ស.វ. និងសាមីខ្លួនដូចមានចែងក្នុងប្រការ៣ ត្រូវអនុវត្ត សេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៧ ក ៦ កើត ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៩

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**យឹម ណុលឡា**

**ចម្លងជូន:**

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៣៧..អនក្រ

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានកំណត់ឲ្យគ្រប់ក្រសួង ស្ថាប័នបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត សម្រាប់ធ្វើការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

**ប្រការ២..**

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាយន្តការនៅអមទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបង្កើតក្រុមការងារដែលមានឈ្មោះថា ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលមានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រីក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង ស្ថាប័នអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ផ្តល់យោបល់ជូនក្រសួង ស្ថាប័ន ក្នុងការរៀបចំរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ធ្វើបច្ចុប្បន្នកម្ម រៀបចំបោះពុម្ព និងផ្សព្វផ្សាយអំពីគោលការណ៍ណែនាំស្តីពីវិធីសាស្ត្រវាយ-តម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

**ប្រការ៣..**

ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួង ស្ថាប័ន ត្រូវទទួលការបណ្តុះបណ្តាលនិងការអនុវត្តសាកល្បង អំពីគោលការណ៍ណែនាំស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

វិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ៤..**

ក្រសួង ស្ថាប័នត្រូវធ្វើការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ខ្លួនដោយអនុវត្តទៅតាមវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត បន្ទាប់ពីក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័ន បានបញ្ចប់ការបណ្តុះ-បណ្តាលនិងការអនុវត្តសាកល្បង។

របាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ត្រូវដាក់ជូនថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័ន ធ្វើជាមូលដ្ឋានសម្រាប់រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត។

**ប្រការ៥..**

ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវសហការជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅតាមក្រសួង ស្ថាប័ន ដើម្បីសិក្សានិងដកពិសោធលើលទ្ធផលការងារអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដែលក្រសួង ស្ថាប័នបានអនុវត្ត។

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័ន ជូនរាជរដ្ឋាភិបាល។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៨ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ